ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សំណុំរឿងព្រហ្មទណ្ឌ
លេខ :១១២០
ចុះថ្ងៃទី២៣-១២-២០១៣

សាលដីកា
លេខ : ១៨ ក្រIV "ច"
ចុះថ្ងៃទី ២៧-០៣-២០១៤

# តាមនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តីដែលប្រកាសឱ្យប្រើតាមក្រិត្យលេខ: ០៦ក្រ ចុះថ្ងៃទី ០៨-០២-១៩៩៣ បានបើកសវនាការជាសាធារណៈ នៅសាលាឧទ្ធរណ៍ នាថ្ងៃទី២៧ ខែមិនា ឆ្នាំ២០១៤ ដោយមាន ៖

**សមាសភាពក្រុមប្រឹក្សា**

លោក [redacted] ជាប្រធានក្រុមប្រឹក្សា
លោក [redacted] ជាចៅក្រមប្រឹក្សា
លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted] ជាព្រះរាជអាជ្ញា

**ក្រឡាបញ្ជី**

លោក [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ : ១១២០ ចុះថ្ងៃទី២៣-១២-២០១៣ រវាង៖

១- ជនជាប់ចោទឈ្មោះ [redacted] លីណាក់ ភេទប្រុស អាយុ២៣ឆ្នាំ សញ្ជាតិខ្មែរ កន្លែងកើត-ទីលំនៅបច្ចុប្បន្ន [redacted] មុខរបរ កសិករ ប្រពន្ធឈ្មោះ [redacted] ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" ទោសពីមុនគ្មាន ។

២- ជនជាប់ចោទឈ្មោះ [redacted] ឃា ភេទប្រុស អាយុ១៨ឆ្នាំ សញ្ជាតិខ្មែរ កន្លែងកើត-ទីលំនៅបច្ចុប្បន្ន [redacted] មុខរបរកសិករ នៅលីវ ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" ទោសពីមុនគ្មាន ។

៣- ជនជាប់ចោទឈ្មោះ [redacted] អេង ភេទប្រុស អាយុ១៨ឆ្នាំ សញ្ជាតិខ្មែរ កន្លែងកើត-ទីលំនៅបច្ចុប្បន្ន [redacted] មុខរបរកសិករ នៅលីវ ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" ទោសពីមុនគ្មាន ។

៣១៨

ត្រូវជាប់ចោទពីបទ : អំពើហិង្សាមានស្ថានទម្ងន់ទោស ដោយមរណៈភាពជនរងគ្រោះ ប្រព្រឹត្តនៅភូមិឪឡឹក ឃុំរំដោះ ស្រុករវៀង ខេត្តព្រះវិហារ កាលពីថ្ងៃទី១២-០២-២០១៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោស តាមបញ្ញត្តិមាត្រា២៤៤ នៃក្រមព្រហ្មទណ្ឌ ។

មានមេធាវីការពារសិទ្ធិ លោក ទូ ចន្ថា។

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទស្រី កើតឆ្នាំ១៩៨៣ សញ្ជាតិខ្មែរ រស់នៅបច្ចុប្បន្នភូមិ [redacted] មុខរបរកសិករ ។

## ឯរឿងហេតុមានដូចតទៅ ៖

កាលពីថ្ងៃទី១២-០២-២០១៣ វេលាម៉ោង២៣:៣០នាទី នៅចំណុចលើស្ពានខាងត្បូងស្ថិតក្នុងភូមិឪឡឹក ឃុំរំដោះ ស្រុករវៀង ខេត្តព្រះវិហារ មានករណីហិង្សាមានស្ថានទម្ងន់ទោសដោយមរណៈភាពជនរងគ្រោះ ដែលបង្កឡើងដោយជនសង្ស័យឈ្មោះ [redacted] លីណាក់ ភេទប្រុស ឈ្មោះ [redacted] ឃា ភេទប្រុស ឈ្មោះ [redacted] អេង ភេទប្រុស បាននាំគ្នាវាយទៅលើជនរងគ្រោះឈ្មោះ [redacted] ឌឿន បណ្តាលឲ្យស្លាប់បាត់បង់ជីវិតនៅថ្ងៃទី១៤-០២-២០១៣ ក្រោយពេលយកទៅមន្ទីរពេទ្យ១៦មករា ខេត្តព្រះវិហារ ។

បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៖ ៩៤ ចុះថ្ងៃទី០៥-១១-២០១៣ របស់សាលាដំបូងខេត្តព្រះវិហារ ដែលមានខ្លឹមសារដូចខាងក្រោម:

១- សម្រេចឲ្យឈ្មោះ [redacted] លីណាក់ ភេទប្រុស ឈ្មោះ [redacted] ឃា ភេទប្រុស ឈ្មោះ [redacted] អេង ភេទប្រុស រួចផុតពីបទចោទ លើអំពើល្មើសត្រូវបានចោទប្រកាន់ពីបទ : ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តឡើងកាលពីថ្ងៃទី១២-០២-២០១៣ ស្ថិតនៅភូមិឪឡឹក ឃុំរំដោះ ស្រុករវៀង ខេត្តព្រះវិហារ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២២៤ នៃក្រមព្រហ្មទណ្ឌ ជនរងគ្រោះឈ្មោះ [redacted] ឌឿន តាមមាត្រា ៣៥០ មាត្រា ៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងមាត្រា៣៨ នៃរដ្ឋធម្មនុញ្ញ ។

២- ផ្តន្ទាទោសឈ្មោះ [redacted] លីណាក់ ភេទប្រុស អាយុ២៣ឆ្នាំ ឈ្មោះ [redacted] អេង ភេទប្រុស អាយុ១៨ឆ្នាំ ឈ្មោះ [redacted] ឃា ភេទប្រុស អាយុ១៨ឆ្នាំ ដាក់ពន្ធនាគារក្នុងម្នាក់ៗ កំណត់ចំនួន០១ឆ្នាំ គិតចាប់ពីថ្ងៃឃុំខ្លួន និងពិន័យជាប្រាក់ម្នាក់ៗចំនួន ២លានរៀល ពីបទ : ហិង្សាដោយចេតនា ទៅលើឈ្មោះ [redacted] ចឿន ប្រព្រឹត្តនៅភូមិឪឡឹក ឃុំរំដោះ ស្រុករវៀង ខេត្តព្រះវិហារ កាលពីថ្ងៃទី១២-០២-២០១៣ តាមបញ្ញត្តិមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ ។

៣- វត្ថុតាងមានស្បែកជើងពីរគូ សម្រេចរឹបអូសបំផ្លាញចោល ។

សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ នៅសាលាដំបូងខេត្តព្រះវិហារ សម្រេចសេចក្តីចំពោះមុខជនជាប់ចោទ នៅថ្ងៃទី២០-១១-២០១៣ ទុកសិទ្ធិឲ្យគូភាគី ដែលអវត្តមានមានសវនាការប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

បានឃើញ ពាក្យបណ្តឹងឧទ្ធរណ៍លេខ១៥ ចុះថ្ងៃទី២០-១១-២០១៣ របស់លោកព្រះរាជអាជ្ញារង [redacted] ស៊ីថា ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៩៤ ចុះថ្ងៃទី៥-១១-២០១៣ របស់សាលាដំបូងខេត្តព្រះវិហារ ប្តឹងឧទ្ធរណ៍នឹងចំណុចទី១ នៃវិនិច្ឆ័យសេចក្តីក្នុងសាលក្រម ។

បានឃើញ របាយការណ៍រឿង របស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍ ចុះថ្ងៃទី០៧-០២-២០១៤ ។

បានឃើញ សេចក្តីសន្និដ្ឋាន របស់ព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ ចុះថ្ងៃទី០៦-០៣-២០១៤ ។

## នាពេលសវនាការ

- ប្រធានក្រុមប្រឹក្សាអានរបាយការណ៍សង្ខេបរឿងក្តី

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ម៉ៅ បានឆ្លើយថា : កាលពីថ្ងៃកើតហេតុនោះ ខ្លួនមិនបានទៅជាមួយប្តីទេ គាត់ទៅរាំការប្អូន ។ មានគេប្រាប់ខ្លួនថា ប្តីខ្លួនត្រូវអ្នកភូមិអំពិលវាយបែកក្បាល ហើយខ្លួនបាននាំគាត់ទៅមន្ទីរពេទ្យ ។ ខ្លួនបានលឺអ្នកដែលទៅពេទ្យជាមួយគ្នាទាំងអស់បាននិយាយគ្នាថា អាណាក់១ ជាអ្នកវាយប្តីខ្លួន ។ ជនជាប់ចោទទាំងបីនាក់នេះ ខ្លួនស្គាល់តែឈ្មោះ ណាក់ ហើយប្តីខ្លួនក៏ស្គាល់ ណាក់ នេះដែរ ព្រោះធ្លាប់ជួលម៉ាស៊ីនបោកស្រូវ ហើយមិនដែលឈ្លោះគ្នានោះទេ ។

- ជនជាប់ចោទឈ្មោះ [redacted] លីណាក់ បានឆ្លើយថា : ពេលប្រតាយប្រតប់គ្នានោះ ខ្លួនមិនបានឃើញគាត់ទេ ខ្លួនមកវិញ គឺមកបីនាក់ ខ្លួនដើរមកពីរាំដល់ស្ពានឃើញឈ្មោះ ចៀន ខ្លួនបានប្រាប់ឈ្មោះ ចៀន ថាខ្លួនទៅដេកហើយ ។ ខ្លួនធ្លាប់ស្គាល់ឈ្មោះ ខឿន ព្រោះធ្លាប់បោកស្រូវជាមួយ ។ ប៉ុន្តែឈ្មោះ ខឿន នេះ ខ្លួនមិនបានវាយទេ ។ ខ្លួនមិនបានឈ្លោះគ្នាជាមួយឈ្មោះ ចៀន ទេ គ្រាន់តែវាយគាត់ ហើយគាត់ក៏វាយក្បាលខ្លួនវិញ គឺគ្រាន់តែវាយគ្នាបានប៉ុណ្ណឹងប៉ុណ្ណោះ ។ ខ្លួនសំណូមពរឲ្យតុលាការបន្ធូរបន្ថយទោស ។

- ជនជាប់ចោទឈ្មោះ [redacted] ឃា បានឆ្លើយថា : ខ្លួនទៅបត់ជើងតូច ឈ្មោះ ចៀន បានទៅវាយខ្លួនពីរបីដៃដួល ហើយបាន ឈ្មោះ [redacted] អេង ជួយ ។ នៅកន្លែងកើតហេតុ មិនមានបក្សពួករបស់ឈ្មោះ ចៀន ទេ មានតែឈ្មោះ ចៀន ម្នាក់ឯងប៉ុណ្ណោះ ។ ខ្លួនមិនដែលស្គាល់ឈ្មោះ ខឿន ទេ ។ ខ្លួនពិតជាកាន់ខ្សែក្រវ៉ាត់រត់មែន ប៉ុន្តែមិនបានយកខ្សែក្រវ៉ាត់នោះវាយគេទេ ខ្លួនវាយពូ ចៀន នឹងដៃប៉ុណ្ណោះ ។ ខ្សែក្រវ៉ាតវារបូត ពេលរត់ផ្លោះចូលព្រៃ ហេតុនេះទើបខ្លួនកាន់វានឹងដៃ ។ ខ្លួនមិនបានឃើញឈ្មោះ ខឿន ទេ ឃើញតែឈ្មោះ ចៀន ដែលមកវាយខ្លួនប៉ុណ្ណោះ ។ សំណូមពរឲ្យតុលាការបន្ធូរបន្ថយទោស ។

- ជនជាប់ចោទឈ្មោះ [redacted] អេង បានឆ្លើយថា : ពេលចេញពីរាំមកដល់ផ្លូវបំបែកចុះពីស្ពានខ្លួនមើលឃើញមានបក្សពួកគេ ហើយក្រោយមកឃើញឈ្មោះ ចៀន នៅតែម្នាក់ឯង ហើយពូ ចៀន នោះបានមកវាយឈ្មោះ [redacted] ឃា ខ្លួនក៏ទៅជួយ ។ ខ្លួនមិនបានវាយឈ្មោះ ខឿន ទេ ហើយក៏មិនបានឃើញគាត់ដែរ ។ ខ្លួនសុំឲ្យតុលាការបន្ធូរបន្ថយទោសដល់ខ្លួនផង ។

- មេឃុំ ឈ្មោះ [redacted] ភារៈ បានឆ្លើយថា : ខ្លួនចង់មកបញ្ជាក់ថា នៅថ្ងៃកើតហេតុនោះ គឺឈ្មោះ ចៀន និងឈ្មោះ ខឿន នៅជាមួយគ្នា ហើយនៅជាមួយនឹងឈ្មោះ ខេន ព្រមទាំងឈ្មោះ ច័ន្ទ មួយទៀត ។

- តំណាងមហាអយ្យការបានសន្និដ្ឋានថា : ជនជាប់ចោទនៅតែប្រកែក ប៉ុន្តែចម្លើយរបស់ជនរងគ្រោះនិងសាក្សី គឺស៊ីសង្វាក់គ្នា ហើយជនជាប់ចោទទាំងបីនាក់នេះក៏មានខ្សែក្រវ៉ាត់នៅនឹងដៃពិតមែន ។ ចម្លើយរបស់លោកមេឃុំនាពេលនេះ ក៏មានលក្ខណៈស៊ីសង្វាក់គ្នាផងដែរ ។ តំណាងមហាអយ្យការយល់ឃើញថាមានភស្តុតាងលើឈ្មោះ [redacted] ឃា ថាបានវាយទៅលើជនរងគ្រោះឈ្មោះ [redacted] ខឿន ពិតប្រាកដមែន តាម

ការពិនិត្យបញ្ជាក់ថា ជនរងគ្រោះស្លាប់ដោយសារប៉ះទង្គិចនឹងវត្ថុរឹង ដែលនេះគឺក្បាលខ្សែក្រវ៉ាត់របស់ឈ្មោះ ឃា នេះឯង ។ ហេតុនេះ សុំឲ្យក្រុមប្រឹក្សាពិនិត្យឡើងវិញ និងសម្រេចជាថ្មី ។

- លោក [redacted] ចន្ថា មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ បានសន្និដ្ឋានថា : ឆ្លងតាមការដេញដោលចំពោះមុខអង្គសវនាការថ្ងៃនេះ កូនក្តីខ្លួនបានឆ្លើយយ៉ាងច្បាស់ហើយថា មិនបានវាយទៅលើឈ្មោះ [redacted] ខឿន ទេ ។ កូនក្តីរបស់ខ្លួនក៏បានសារភាពដែរថា ខ្លួនបានវាយតែឈ្មោះ ចៀន តែប៉ុណ្ណោះ ។ តាមការពិនិត្យ តើជនរងគ្រោះប៉ះទង្គិចអ្វីទើបបណ្តាលឲ្យស្លាប់ តែក្នុងរឿងនេះគ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់មកលើកូនក្តីខ្លួននោះទេ ។ សូមសំណូមពរដល់ក្រុមប្រឹក្សាមេត្តាសម្រេចតម្កល់សាលក្រមព្រហ្មទណ្ឌរបស់សាលាដំបូងខេត្តព្រះវិហារទុកជាបានការដដែល ។

- ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទទាំងបីនាក់
- ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានពិចារណាលើគ្រប់ឯកសារ និងភស្តុតាងផ្សេងៗ
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

<u>សំអាងហេតុ</u>

យល់ឃើញថា

១- ពាក្យបណ្តឹងឧទ្ធរណ៍របស់លោកព្រះរាជអាជ្ញារង [redacted] ស៊ីថា ចុះថ្ងៃទី២០-១១-២០១៣ ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៩៤ “ខ” ចុះថ្ងៃទី០៥-១១-២០១៣ របស់សាលាសាលាដំបូងខេត្តព្រះវិហារ ត្រង់ចំណុចទី១ នៃវិនិច្ឆ័យសេចក្តី ធ្វើឡើងក្នុងកំណត់ច្បាប់ យោងតាមមាត្រា ៣៨១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះបាន ។

២- ជនជាប់ចោទឈ្មោះ [redacted] លីណាក់ ឈ្មោះ [redacted] ឃា និងឈ្មោះ [redacted] អេង បានឆ្លើយបដិសេធប្រហាក់ប្រហែលគ្នានាពេលសវនាការសាលាឧទ្ធរណ៍ថា : ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ ថ្ងៃកើតហេតុនោះ ខ្លួនបានឃើញតែឈ្មោះ ចៀន ហើយបានវាយតែឈ្មោះ ចៀន ប៉ុណ្ណោះ មិនបានឃើញឈ្មោះ ខឿន ទេ ។ ចម្លើយដោះសាររបស់ជនជាប់ចោទទាំងបីនាក់នេះ មិនមានមូលដ្ឋានអាចឲ្យក្រុមប្រឹក្សាជឿបានទេ ដោយហេតុថា តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] ចៀន ដែលបានឆ្លើយនៅគ្រប់ដំណាក់កាលប្រហាក់ប្រហែលគ្នាថា : នៅថ្ងៃកើតហេតុបន្ទាប់ពីចេញពីរាំ ខ្លួនបានជួបនឹងឈ្មោះ [redacted] ខឿន និងឈ្មោះ ខេង ហើយក៏បានដើរទៅផ្ទះជាមួយគ្នា បានជួបជាមួយនឹងឈ្មោះ ណាក់ និងមនុស្សពីរនាក់ទៀតមិនស្គាល់ឈ្មោះ ហើយក៏មានរឿងវាយតប់គ្នាតែម្តង ពេលនោះខ្លួនបានឃើញមនុស្សម្នាក់មិនស្គាល់ឈ្មោះ បានហូតខ្សែក្រវ៉ាត់ពីចង្កេះខោមកវាយខ្លួន និងឈ្មោះ ខឿន បែកក្បាល (ឯកសារលេខ៧, ៤៦ និង៦០) ។ ចម្លើយរបស់ឈ្មោះ [redacted] ចៀន នេះ ក៏មានលក្ខណៈស្របគ្នាទៅនឹងចម្លើយរបស់សាក្សីឈ្មោះ [redacted] សុខេង ដែលបានឆ្លើយថា : ពេលចេញពីកន្លែងរាំ ខ្លួនបានជួបនឹងឈ្មោះ [redacted] ខឿន និងឈ្មោះ [redacted] ចៀន និយាយជាមួយឈ្មោះ

ណាក់ និងមនុស្សពីរនាក់ទៀតមិនស្គាល់ឈ្មោះ ពេលនោះឈ្មោះ ណាក់ ចាប់ក្បាលឈ្មោះ ចៀន បន្ទាប់មក ក៏មានអ្នកកាន់ខ្សែក្រវ៉ាត់ វាយលើឈ្មោះ ចៀន និងឈ្មោះ ខឿន ដួល (ឯកសារលេខ ៦ និងលេខ៦០) ។ ចម្លើយនេះ ក៏មានលក្ខណៈស្របគ្នាទៅនឹងចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted]លីណាក់ ដែលបញ្ជាក់ថា ថ្ងៃកើតហេតុខ្លួនបានជួបឈ្មោះ [redacted]ចៀន និងមានអ្នកផ្សេងទៀតដែលខ្លួនមិនស្គាល់ (ឯកសារលេខ៦០) ។

តាមចម្លើយរបស់ឈ្មោះ [redacted] ចៀន និងឈ្មោះ [redacted]សុខេង និងចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] លីណាក់ ខាងលើ សបញ្ជាក់ឲ្យឃើញថានៅកើតហេតុឈ្មោះ [redacted] ខឿន និងឈ្មោះ [redacted] ចៀន បានដើរជាមួយគ្នា ហើយក៏បានជួបនឹងឈ្មោះ [redacted]លីណាក់ ឈ្មោះ [redacted] យា និងឈ្មោះ [redacted] អេង ហើយ ឈ្មោះ [redacted] ខឿន ក៏បានចូលរួមវាយគ្នាជាមួយជនជាប់ចោទទាំងបីនាក់ខាងលើ ពិតប្រាកដមែន ។

៣- ក្រុមប្រឹក្សាយល់ឃើញថា ទោះបីជាជនជាប់ចោទឈ្មោះ [redacted] យា បានឆ្លើយបដិសេធថា ខ្លួនមិន បានវាយជនរងគ្រោះដោយប្រើខ្សែក្រវ៉ាត់ទេ គឺខ្សែក្រវ៉ាត់ខ្លួនកាន់ ព្រោះវារបូត ពេលខ្លួនរត់ផ្លោះ ។ ប៉ុន្តែចម្លើយ ដោះសារនេះ មិនមានមូលដ្ឋានអាចឲ្យក្រុមប្រឹក្សាជឿបានទេ ដោយហេតុថា យោងតាមចម្លើយរបស់ឈ្មោះ [redacted] ចៀន និងចម្លើយរបស់សាក្សីឈ្មោះ [redacted] សុខេង ដែលបានបញ្ជាក់ថា បានឃើញមនុស្សម្នាក់ហូត ខ្សែក្រវ៉ាត់ពីចង្កេះខោ វាយទៅលើឈ្មោះ [redacted] ខឿន ។ ហេតុនេះ មានលក្ខណៈស៊ីសង្វាក់ទៅនឹងភស្តុតាងជា កាលៈទេសៈ ដែលអាចបញ្ជាក់បានថា ជនរងគ្រោះឈ្មោះ [redacted] ខឿន ត្រូវបានជនជាប់ចោទឈ្មោះ [redacted] លីណាក់ ឈ្មោះ [redacted] យា និងឈ្មោះ [redacted] អេង វាយ បណ្តាលឲ្យស្លាប់ ពិតប្រាកដមែន ។

៤- សេចក្តីសន្និដ្ឋានរបស់លោកមេធាវី [redacted] ចន្ថា មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទទាំងបីនាក់ថា : គ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់មកលើកូនក្តីខ្លួននោះទេ សុំក្រុមប្រឹក្សាសម្រេចតម្កល់សាលក្រមព្រហ្មទណ្ឌ របស់សាលាដំបូងខេត្តព្រះវិហារទុកជាបានការដដែល ។ ក្រុមប្រឹក្សាយល់ថា តាមចម្លើយរបស់ជនជាប់ ចោទ និងចម្លើយរបស់សាក្សីទាំងអស់ខាងលើ អាចជាមូលដ្ឋានឲ្យក្រុមប្រឹក្សាពិចារណាបានថា អំពើប្រព្រឹត្ត របស់ជនជាប់ចោទទាំងបីនាក់ខាងលើ គឺជាសហចារីនៃបទល្មើស ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ដោយសារមរណភាពនៃជនរងគ្រោះ ស្របតាមបញ្ញត្តិនៃមាត្រា ២២៤ នៃក្រមព្រហ្មទណ្ឌ ដែលគប្បីក្រុម ប្រឹក្សាពិចារណា ។

៥- តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍បានសន្និដ្ឋានថា : មានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ពី ពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ [redacted] លីណាក់ ឈ្មោះ [redacted] យា និងឈ្មោះ [redacted] អេង ថាបានវាយទៅ លើជនរងគ្រោះឈ្មោះ [redacted] ខឿន ពិតប្រាកដមែន សុំឲ្យក្រុមប្រឹក្សាពិនិត្យឡើងវិញ និងសម្រេចជាថ្មី ។ សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ មានលក្ខណៈត្រឹមត្រូវ គប្បីក្រុមប្រឹក្សា ពិចារណា និងសម្រេច ។

៦- សាលក្រមព្រហ្មទណ្ឌលេខ ៩៤ “ខ” ចុះថ្ងៃទី០៥-១១-២០១៣ របស់សាលាសាលាដំបូងខេត្ត ព្រះវិហារ ដែលបានសម្រេចសេចក្តីមកនេះ មានលក្ខណៈពុំត្រឹមត្រូវតាមគតិច្បាប់ខ្លះ ដែលគប្បីសាលា ឧទ្ធរណ៍បដិសេធចោលចំណុច ដែលមិនត្រឹមត្រូវតាមគតិច្បាប់ ហើយសម្រេចជាថ្មីតាមការយល់ឃើញខាង លើ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១- ទទួលពាក្យបណ្តឹងឧទ្ធរណ៍របស់លោកព្រះរាជអាជ្ញារង [redacted] ស៊ីថា ចុះថ្ងៃទី២០-១១-២០១៣ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ និងគតិច្បាប់ ។

២- បដិសេធចោលចំណុចទី១ នៃវិនិច្ឆ័យសេចក្តី នៃសាលក្រមព្រហ្មទណ្ឌលេខ ៩៤ "ខ" ចុះថ្ងៃទី០៥-១១-២០១៣ របស់សាលាសាលាដំបូងខេត្តព្រះវិហារ ។

៣- ផ្តន្ទាទោស

- ឈ្មោះ [redacted] លីណាក់
- ឈ្មោះ [redacted] ឃា
- ឈ្មោះ [redacted] អេង

ដាក់ពន្ធនាគារកំណត់ ០៧ (ប្រាំពីរ) ឆ្នាំ ក្នុងម្នាក់ៗ គិតចាប់ពីថ្ងៃឃុំខ្លួន ពីបទ : ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ដោយសារមរណភាពនៃជនរងគ្រោះ ប្រព្រឹត្តលើជនរងគ្រោះឈ្មោះ [redacted] ខឿន តាមបញ្ញត្តិមាត្រា២២៤ នៃក្រមព្រហ្មទណ្ឌ ។

ចំណុចក្រៅពីនេះ រក្សាទុកជាបានការដដែល ។

៤- បន្តឃុំខ្លួនជនជាប់ចោទតាមនីតិវិធីច្បាប់ ។

សាលដីកានេះ ជំនុំជម្រះជាសាធារណៈ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៧-០៣-២០១៤ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] លីណាក់, [redacted] អេង និង ញ៉ឹប ឃា និងចំពោះមុខមេធាវីការពារសិទ្ធិ ។

បើកសិទ្ធិប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ គ្រប់តំណែង និងកងកម្លាំងប្រដាប់អាវុធ ជួយសហការអនុវត្តសាលដីកានេះឲ្យបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|
| ហត្ថលេខា [redacted] | ហត្ថលេខា [redacted] , [redacted] | ហត្ថលេខា [redacted] |

បានឃើញ
ប្រធានសាលាឧទ្ធរណ៍

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែ វិច្ឆិកា ឆ្នាំ២០១៤
ក្រឡាបញ្ជី

[redacted]

៣២៤